# ការអប់រំពិសេស
# ពាក្យ និង អត្ថន័យ
# Special Education
# Terms and Definitions

បញ្ជីខាងក្រោមនេះមាន ពាក្យសម្រាប់ការអប់រំពិសេស អត្ថន័យ និងអក្សរកាត់ ដែលប្រើជាទូទៅដោយសាលា និងការរៀបចំ **គម្រោងការអប់រំផ្ទាល់ខ្លួន (IEP)** របស់ក្មេង។/ The following list contains special education terms, definitions and acronyms that are commonly by schools and the **Individualized Education Plan (IEP)** process.

**កម្មវិធីកាយវប្បកម្មដែលមានលក្ខណៈសម្របសម្រួល៖** កម្មវិធីកាយវប្បកម្មដែលបានរៀបចំជាពិសេស តាមសំណូមពរ ដែលបានរៀបចំឡើងឲ្យត្រូវតាមក្តីត្រូវការរបស់សិស្សានុសិស្ស ដែលតម្រូវឲ្យមាន ការរីកចម្រើន ឬការកែតម្រូវការបង្ហាត់បង្រៀន ផ្នែកកាយវប្បកម្ម។/
**Adapted Physical Education (APE):** Specially designed physical education program, using accommodations designed to fit the needs of students who require developmental or corrective instruction in physical education.

**ការរៀបចំឲ្យសមតាមសេចក្តីត្រូវការ៖** ការផ្លាស់ប្តូរដែលអនុញ្ញាតឲ្យមនុស្សពិការអាចចូលរួម បានពេញលេញក្នុងសកម្មភាពអ្វីមួយ។ ឧទាហរណ៍ រួមមាន ផ្តល់ឲ្យពេលវេលាបន្ថែម របៀបប្រឡងខុសប្លែកពីគេ និងការផ្លាស់ប្តូរបរិយាកាសក្នុងថ្នាក់រៀន។/
**Accommodations:** Changes that allow a person with a disability to participate fully in an activity. Examples include extended time, different test format, and alterations to a classroom environment.

**បញ្ហាក្នុងការផ្ចង់អារម្មណ៍ (ADD)/ បញ្ហានៅមិនស្ងៀម មិនអាចផ្ចង់អារម្មណ៍ (ADHD)៖** **បញ្ហានៅមិនស្ងៀម មិនអាចផ្ចង់អារម្មណ៍** គឺជាអាការៈរោគ ដែលធ្វើឲ្យក្មេង មិនអាចផ្ចង់អារម្មណ៍ទៅលើអ្វីមួយ នៅពេលដែលក្មេងធ្វើអ្វីទៅតាមតែសន្ទុះចិត្ត និង/ឬ គ្មានការប្រុងប្រយ័ត្ន ហើយនៅមិនស្ងៀម។ ADD និង ADHD គឺជាពាក្យសម្រាប់វិជ្ជាពេទ្យ មិនមែនជាពាក្យប្រើនៅក្នុងអប់រំទេ។ វាអាចធ្វើឲ្យសិស្សមានសិទ្ធិចូលរួមក្នុងសេវាអប់រំពិសេស ក្រោមជំពូកនៃ**បញ្ហាសុខភាពផ្សេងទៀត (OHI)**។/
**ADD/ADHD: Attention Deficit Disorder (ADD)** and **Attention Deficit Hyperactivity Disorder (ADHD)** are medical conditions characterized by a child's inability to focus, while possessing impulsivity and/or inattention and hyperactivity. ADD and ADHD are medical not educational terms. They may qualify a student for special education services under the heading of **Other Health Impairment (OHI).**

**ការវាយតម្លៃ៖** ពាក្យនេះប្រើដើម្បីពិពណ៌នាការពិនិត្យទាំងអស់ និងវិធីវិនិច្ឆ័យរោគ ដើម្បីបង្កើតគម្រោងការអប់រំផ្ទាល់ខ្លួនរបស់ក្មេង **(IEP)** ដ៏សមរម្យ សម្រាប់សិស្សដែលត្រូវការ ការអប់រំពិសេស។/
**Assessment or Evaluation:** Term used to describe all of the testing and diagnostic processes leading up to the development of an appropriate **Individualized Education Plan (IEP)** for a student with special education needs.

**Asperger's Syndrome:** ប្រភេទ **បញ្ហានៃការលូតលាស់ដែលខុសពីធម្មតា (PDD)** គឺជាការសម្គាល់លក្ខណៈដែលមានបញ្ហាធ្ងន់ធ្ងរ ក្នុងការ ធ្វើទំនាក់ទំនងក្នុងសង្គម និងការអភិវឌ្ឍន៍នៃអាកប្បកិរិយាដដែលៗ ចំណាប់អារម្មណ៍ និង សកម្មភាពផ្សេងៗ។/
**Asperger's Syndrome:** A type of **Pervasive Developmental Disorder (PDD)** characterized by severe impairment in social interaction and the development of limited, repetitive patterns of behavior, interests, and activities.

**ជំងឺខួរក្បាលពីកំណើត៖** ខួរក្បាលដែលរីកចម្រើនខុសពីធម្មតា គឺជាការសម្គាល់លក្ខណៈដែលមានបញ្ហាក្នុងការ ធ្វើទំនាក់ទំនងក្នុងសង្គម និយាយស្តី និង ការមានកំណត់ និងភាពច្រំដែល នៃអាកប្បកិរិយា ចំណាប់អារម្មណ៍ និង សកម្មភាពផ្សេងៗ។ រោគសញ្ញានេះចាប់ផ្តើមឡើងមុនពេលក្មេងមានអាយុ៣ឆ្នាំ។/
**Autism:** A brain development disorder characterized by impaired social interaction, communication and by restricted and repetitive behavior, interests, and activities. Signs begin before a child is 3 years old.

**គម្រោងការធ្វើអន្តរាគមន៍លើអាកប្បកិរិយា (BIP)៖** ពាក្យសម្រាប់ការអប់រំពិសេស ប្រើដើម្បីពិពណ៌នាពីការសរសេរគម្រោងការដែលប្រើដើម្បីដោះស្រាយបញ្ហានៃអាកប្បកិរិយា រួមមាន ការធ្វើអន្តរាគមន៍ឲ្យមានអាកប្បកិរិយាល្អ គម្រោងផែនការ និងការគាំទ្រ។ អាចរួមទាំង ការកែសម្រួលកម្មវិធី និងជំនួយបន្ថែម និងការបម្រើផ្សេងៗ។/
**Behavior Intervention Plan (BIP):** Special education term used to describe the written plan used to address problem behavior that includes positive behavioral interventions, strategies and support. May include program modifications and supplementary aids and services.

**ខ្វាក់៖** អាការរោគដែលធ្វើមិនឲ្យមើលឃើញ ដោយសារកត្តានៃ រូបកាយ ឬ ប្រព័ន្ធសរសៃប្រសាទ ផ្សេងៗ។/
**Blindness:** Condition of lacking visual perception due to physiological or neurological factors.

**វិកលចលនាសរសៃញ្ញាណ (CP)៖** បញ្ហាជាច្រើននៃ ការធ្វើចលនា និងសរីរាងកាយ ដែលមានការទាក់ទងទៅនឹងរបួសខួរក្បាល។ រោគ **វិកលចលនាសរសៃញ្ញាណ** បណ្តាលឲ្យមានការញាក់ញ័រ ដែលមិនអាចទប់បាន និងតឹងសាច់ដុំ ហើយអាចបណ្តាលឲ្យមានបញ្ហាដល់តុល្យភាព និង ចក្ខុន្ទ្រិយ។ ក្នុងករណីធ្ងន់ធ្ងរ អាចបណ្តាលឲ្យមានបញ្ហា ខួរក្បាល ឆ្កួតជ្រូក ឬ មានបញ្ហាភ្នែក និងត្រចៀក។/
**Cerebral Palsy (CP):** A series of motor problems and physical disorders related to brain injury. **Cerebral Palsy (CP)** causes uncontrollable reflex movements and muscle tightness and may cause problems in balance and depth perception. Severe cases can result in intellectual disability, seizures or vision and hearing problems.

**សំណុំឯកសារ៖** ឯកសារដែលរក្សាទុកដោយក្រសួងអប់រំក្នុងតំបន់ សម្រាប់ក្មេងដែលបានចុះឈ្មោះរៀន។ ឯកសារនេះប្រហែលជាមាន ការវាយតម្លៃ និងព័ត៌មានអំពី ពិការភាព និងការចាត់តាំងក្មេង។ ហើយក៏មានពិន្ទុ និងលទ្ធផលនៃការវាយតម្លៃតាមខ្នាតទូទៅផងដែរ។ មាតាបិតាមានសិទ្ធិពិនិត្យមើលសំណុំឯកសារទាំងនេះនៅពេលណាក៏បាន។/
**Cumulative File:** The records maintained by the local school district for any child enrolled in school. The file may contain evaluations and information about a child’s disability and placement. It also contains grades and results of standardized assessments. Parents have the right to inspect these files at any time.

**ថ្លង់៖** វិកលសោតវិញ្ញាណ ដែលប៉ះពាល់ដល់សមត្ថភាពរបស់ក្មេង ក្នុងការស្វែងយល់ និងទទួលយកព័ត៌មានដែលគេបាននិយាយ។
**Deafness:** Hearing impairment that affects a child’s ability to comprehend and process verbally presented information.

**ពិការភាព៖** វិកលសរីរាង្គកាយ ឬវិកលខួរក្បាល ដែលជាឧបស័គ្គមិនអាចឲ្យបុគ្គលធ្វើសកម្មភាពអ្វីមួយ ឬសកម្មភាពជាច្រើន នៅក្នុងជីវិត។/
**Disability:** Physical or mental impairment that substantially limits one or more major life activities.

**សិទ្ធិតាមច្បាប់៖** ពាក្យសម្រាប់ការអប់រំពិសេស ប្រើដើម្បីពិពណ៌នាពីវិធីដែលមាតាបិតាអាចមិនយល់ស្របជាមួយសំណូមពរកម្មវិធីរបស់ក្រសួងអប់រំ ឬការខ្វះខាតត្រង់ចំណុចដែលបានចែង នៃកិច្ចព្រមព្រៀង អំពីការបម្រើផ្សេងៗ។ **ច្បាប់នៃការអប់រំសិស្សពិការ (IDEA)** ផ្តល់វិធីពីរយ៉ាង សម្រាប់ដោះស្រាយការខ្វែងគំនិត បើសិនជាគ្មានការព្រមព្រៀងគ្នាតាមវិធីណាមួយ ជួយសម្រួលដំណោះស្រាយ ឬ សវនាការរកខុសត្រូវដោយយុត្តិធម៌។/

**Due Process:** Special education term used to describe the process where parents may disagree with the program recommendations of the school district or the lack of provision of agreed upon services. **Individuals with Disabilities Education Act (IDEA)** provides two methods for resolving disputes if agreement cannot be reached in any other way, mediation or fair hearing.

**ធ្វើអន្តរាគមន៍ជួយកុមារទាន់នៅក្មេង៖** កម្មវិធីសម្រាប់ ទារកដែលក្រចេះធ្វើអ្វី និងក្មេងអាយុពីរបីឆ្នាំ មុនពេលគ្រប់អាយុចូលរៀន ដែលបានរៀបចំដើម្បីជួយការពារបញ្ហា ពេលក្មេងចម្រើនវ័យ។/

**Early Intervention:** Programs for developmentally delayed infants and toddlers prior to school-age entry; designed to help prevent problems as the child matures.

**ឆាប់មានការវិខានក្នុងចិត្ត (ED)៖** ពាក្យប្រើដើម្បីពិពណ៌នាអំពី ខួរក្បាល អាកប្បកិរិយា ឬផ្លូវចិត្ត ដែលអាចធ្វើរោគវិនិច្ឆ័យបាន ដែលមានការប៉ះពាល់ដល់ការសិក្សា និងមានភាពជាក់ស្តែង និងក្នុងរយៈពេលយូរ។/

**Emotional Disturbance (ED):** Term used to describe a diagnosable mental, behavioral or emotional disorder that adversely affects academic performance and is evident to a marked degree and over a long period of time.

**សេវាបន្ថែមថ្ងៃសិក្សាប្រចាំឆ្នាំ (ESY)៖** ការបន្ថែមថ្ងៃសិក្សាប្រចាំឆ្នាំ គឺជាសេវាអប់រំពិសេស សម្រាប់សិស្សានុសិស្សដែលមានការត្រូវការខុសប្លែកពីគេ ដែលត្រូវការសេវាផ្សេងៗថែមទៀត លើសពីឆ្នាំសិក្សាធម្មតា។ សិស្សានុសិស្សត្រូវតែបង្ហាញថា បើគ្មានសេវាបន្ថែមថ្ងៃសិក្សាប្រចាំឆ្នាំ នឹងមានការចុះថយដល់ចំណេះដឹង និងពេលវេលាដែលបានតម្រូវដើម្បីឲ្យបានមកវិញនូវការបាត់បង់នោះនឹងមានច្រើន។/

**Extended School Year Services (ESY):** Extended school year is special education services for students with unique needs who require services in excess of the regular academic year. Students have to demonstrate that without the ESY services there would be a regression of skills and the time required to recoup those losses would be significant.

**ការអប់រំជាសាធារណៈដែលសមរម្យដោយឥតគិតថ្លៃ (FAPE)៖** ការអប់រំពិសេស និងការបម្រើផ្សេងៗដែលក្មេងត្រូវការ ដើម្បីឲ្យពួកគេអាចចូលរួមក្នុងកម្មវិធីអប់រំ និងដែលបានផ្តល់ឲ្យមាតាបិតាដោយឥតគិតថ្លៃ។/

**Free Appropriate Public Education (FAPE):** Special education and related services required by a child to enable them to access the educational program and which are provided without charge to the parents.

**ការវាយតម្លៃអាកប្បកិរិយា (FBA)៖** វិធីសង្កេតមើលអាកប្បកិរិយារបស់សិស្ស ដើម្បីសម្រេចនូវកត្តាផ្សេងៗដែលនាំឲ្យមានអាកប្បកិរិយាបែបនេះ និងលទ្ធផលដែលរក្សាអាកប្បកិរិយាល្អ។/

**Functional Behavioral Assessment (FBA):** A way of looking at student behavior to determine the factors that contribute to the behavior and the outcomes that maintain the behavior.

**មានបញ្ហាជាមួយសោតវិញ្ញាណ៖** សម្ថភាពដែលធ្វើឲ្យដឹង ឬយល់សម្លេង មានការចុះថយខ្លាំង ឬចុះថយមួយចំនួន។/

**Hearing Impairment:** Full or partial decrease in the ability to detect or understand sounds.

**ការដាក់បញ្ចូល៖** ពាក្យប្រើដើម្បីពិពណ៌នាការបម្រើដែលដាក់សិស្សពិការឲ្យរៀនក្នុង ថ្នាក់ទូទៅ ដោយមានសេវាគាំទ្រដែលសមរម្យ។/

**Inclusion:**Term used to describe service that places students with disabilities in general education classrooms with appropriate support services.

**ច្បាប់អប់រំសិស្សពិការ (IDEA) នៃឆ្នាំ ២០០៤៖** សភាបានអនុម័តច្បាប់ដែលឲ្យនិយមន័យ និងសន្យានូវខដែលបានចែងអំពីសេវាអប់រំពិសេស។/

**Individuals with Disabilities Education Act (IDEA) of 2004:** The law passed by Congress which defines and guarantees the provisions of special education services.

**គម្រោងការអប់រំផ្ទាល់របស់ក្មេង (IEP)៖** ពាក្យសម្រាប់ការអប់រំពិសេសដែលប្រើដោយ**ច្បាប់អប់រំសិស្សពិការ (IDEA)** ដើម្បីឲ្យនិយមន័យដល់ឯកសារដែលនិយាយអំពី គោលបំណង និងការបម្រើផ្សេងៗសម្រាប់សិស្សានុសិស្សដែលទទួល ការអប់រំពិសេស។/

**Individualized Education Plan (IEP):** Special education term used by **Individuals with Disabilities Education Act (IDEA)** to define the written document that states goals, objectives and services for students receiving special education.

**ការវាយតម្លៃការអប់រំជាឯកជន (IEE)៖** ច្បាប់បានតម្រូវឲ្យក្រសួងអប់រំធ្វើការវាយតម្លៃសិស្សានុសិស្សដែលអាចទទួលការអប់រំពិសេស។ បើសិនជាមាតាបិតាមិនយល់ស្របតាមលទ្ធផលនៃការវាយតម្លៃរបស់ក្រសួងអប់រំ ដែលបានវាយតម្លៃកូនរបស់គាត់ ពួកគាត់មានសិទ្ធិស្នើសុំឲ្យមានការវាយតម្លៃការអប់រំជាឯកជន។ ក្រសួងត្រូវតែផ្តល់ព័ត៌មានអំពីរបៀបសុំ **ការវាយតម្លៃការអប់រំជាឯកជន (IEE)**។ ការវាយតម្លៃការអប់រំជាឯកជន មានន័យថា ការវាយតម្លៃដែលធ្វើឡើងដោយអ្នកពិនិត្យម្នាក់ ដែលមានសមត្ថភាព ដែលមិនមែនជាបុគ្គលិករបស់ក្រសួងអប់រំ។/

**Independent Educational Evaluation (IEE):** A school district is required by law to conduct assessments for students who may be eligible for special education. If the parent disagrees with the results of a school district's evaluation conducted on their child, they have the right to request an independent educational evaluation. The district must provide information about how to obtain an **Independent Educational Evaluation (IEE)**. An independent educational evaluation means an evaluation conducted by a qualified examiner who is not employed by the school district.

**គម្រោងការបម្រើក្រុមគ្រួសារ នីមួយៗ (IFSP)៖** វិធីធ្វើអន្តរាគមន៍ជួយកុមារទាន់នៅក្មេង សម្រាប់ក្មេងដែលមានអាយុ ០-៣ ឆ្នាំ ដែលត្រូវការជំនួយពិសេស។ សេចក្តីត្រូវការសំខាន់ៗរបស់ក្រុមគ្រួសារត្រូវបានគេបង្ហាញឲ្យឃើញ ហើយចាប់ផ្តើមការសរសេរគម្រោងការណ៍ និងពិនិត្យមើលឲ្យបានទៀងទាត់។/

**Individualized Family Service Plan: (IFSP):** A process of providing early intervention services for children ages 0-3 with special needs. Family based needs are identified and a written plan is developed and reviewed periodically.

**គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ (ITP)៖** គម្រោងការនេះចាប់ផ្តើមនៅពេលក្មេងមានអាយុ១៤ឆ្នាំ ហើយនិយាយអំពី សកម្មភាពក្រោយម៉ោងរៀន ក្រោយពេលរៀនចប់ពីវិទ្យាល័យ ការងារ បទពិសោធន៍ក្នុងសហគមន៍ និងចំណេះដឹងក្នុងការរស់នៅប្រចាំថ្ងៃ។/

**Individualized Transition Plan (ITP):** This plan starts at age 14 and addresses areas of post-school activities, post secondary education, employment, community experiences and daily living skills.

**សិស្សពិការដែលមាន បញ្ញាវាងវៃ (ID)៖** ពាក្យប្រើដើម្បីពិពណ៌នាសិស្សានុសិស្សដែលមាន បញ្ញា និង ចំណេះដឹង ក្នុងការរស់នៅប្រចាំថ្ងៃ ជាមធ្យមភាគ។/

**Intellectual Disability (ID):** Term used to describe students who have subaverage intelligence and adaptive skills of daily living.

**បរិយាកាសដែលមិនសូវមានការដាក់កំណាត់ (LRE)៖** ការចាត់តាំងសិស្សពិការក្នុងលក្ខណៈ ធ្វើឲ្យមានការប្រស្រ័យទាក់ទងយ៉ាងពេញទំហឹងជាមួយសិស្សសាលាទូទៅ។ ការជ្រើសរើសក្នុងការចាត់តាំងសិស្ស ត្រូវផ្តល់ឲ្យតាមការធ្វើតៗគ្នា ដែលមិនអាចវែកញែកបាន រួមទាំងថ្នាក់រៀនធម្មតាដែលគ្មានសេវាគាំទ្រ ថ្នាក់រៀនធម្មតាដែលមានសេវាគាំទ្រ សេវាបង្ហាត់បង្រៀនដែលបានចាត់តាំង ថ្នាក់រៀននៅថ្ងៃពិសេស និងកម្មវិធីអប់រំពិសេសជាឯកជន។/

**Least Restrictive Environment (LRE):** The placement of a special needs student in a manner promoting the maximum possible interaction with the general school population. Placement options are offered on a continuum including regular classroom with no support services, regular classroom with support services, designated instruction services, special day classes and private special education programs.

**ទាតច្រើន៖** ពាក្យប្រើដើម្បីពិពណ៌នាអំពីការរួមបញ្ចូលរបស់ក្មេងពិការ ទៅក្នុងថ្នាក់រៀនធម្មតា សម្រាប់ម៉ោងខ្លះ។ ម៉ោងផ្សេងទៀត រៀននៅក្នុងថ្នាក់អប់រំពិសេស។/
**Mainstreaming:** Term used to describe the integration of children with special needs into regular classrooms for part of the school day. The remainder of the day is in a special education classroom.

**ការសម្រេចចិត្ត អំពីអ្វីដែលបានបង្ហាញឡើង៖** ក្នុងកំឡុងពេល១០ថ្ងៃរៀន នៃការសម្រេចចិត្តណាមួយ ដើម្បីផ្លាស់ប្តូរការចាត់តាំងក្មេងពិការ ដោយសារការបំពានលើក្រមសីលធម៌ របស់សាលា **ក្រុមធ្វើ គម្រោងការអប់រំផ្ទាល់របស់ក្មេង (IEP)** ត្រូវតែពិនិត្យព័ត៌មានដែលជាប់ទាក់ទងទាំងអស់ ក្នុងសំណុំឯកសាររបស់សិស្ស ដើម្បីសម្រេចថាតើទង្វើដែលគេចោទប្រកាន់ បណ្តាលមកពីពិការភាពរបស់ក្មេង ឬទង្វើនោះជាលទ្ធផលរបស់ក្រសួងអប់រំដែលមិនធ្វើ **គម្រោងការអប់រំផ្ទាល់របស់ក្មេង**។/
**Manifestation Determination:** Within 10 school days of any decision to change the placement of a child with a disability because of violation of school code, the **Individualized Education Plan (IEP)** team must review all relevant information in the student's file to determine if the conduct in question was caused by the child's disability or if the conduct was a direct result of the school district's failure to implement the child's **Individualized Education Plan (IEP)**.

**អ្នកបង្រៀនឲ្យធ្វើអ្វីៗដែលមានប្រយោជន៍នៅក្នុងការរស់នៅ៖** ផ្តល់ការពិគ្រោះ និងការគាំទ្រ ដល់បុគ្គលិកដើម្បីបង្កើនការសិក្សារបស់សិស្ស ដែលទាក់ទងនឹងការប្រើសាច់ដុំតូចដើម្បីធ្វើចលនា ការប្រើសាច់ដុំធំដើម្បីធ្វើចលនា និងការអភិវឌ្ឍន៍តាមការរួមបញ្ចូលវិញ្ញាណ។/
**Occupational Therapists:** Provide consultation and support to staff to improve a student's educational performance related to fine motor, gross motor and sensory integration development.

**ក្មេងមានបញ្ហាមិនស្តាប់បង្គាប់ (ODD)៖** បញ្ហាដែលក្មេងមិនស្តាប់បង្គាប់អាជ្ញាធម៌ដោយ មិនគោរព តមាត់ ឈ្លោះប្រកែក ឬក្រញេងក្រញាងហួសហេតុ បើប្រៀបធៀបទៅនឹងក្មេងឯទៀតៗដែលមានអាយុដូចគ្នា ហើយកើតមានឡើងច្រំដែលៗជាបន្តអស់រយៈពេលប្រាំមួយខែឡើងទៅ។/
**Oppositional Defiant Disorder (ODD):** A condition in which a child defies authority by disobeying, talking back, arguing or being hostile in a way that is excessive, compared to other children of the same age and this pattern continues for more than six months.

**ការអន់ថយរូបកាយ៖** ពាក្យប្រើដើម្បីឲ្យនិយមន័យនៃការអន់ថយ ដែលមិនធម្មតាពីកំណើត ការអន់ថយដោយសារជម្ងឺ និងការអន់ថយដោយសារមូលហេតុផ្សេងៗទៀត ដែលប៉ះពាល់ដល់ ឆ្អឹង និងសាច់ដុំ របស់បុគ្គល។/
**Orthopedic Impairment:** Term used to define impairments caused by congenital anomaly, impairments by diseases and impairments by other causes that affect the bones and muscles of individuals.

**ការអន់ថយសុខភាពផ្សេងទៀត៖** ពាក្យប្រើដើម្បីពិពណ៌នាអំពី កម្លាំង ភាពក្លៀវក្លា និងការឈ្លាសវៃ ដែលមានកម្រិត បណ្តាលឲ្យចុះថយសមត្ថភាព ក្នុងបរិយាកាសអប់រំ។ ការអន់ថយដែលអាចបណ្តាលមកពី បញ្ហាសុខភាពរ៉ាំរ៉ៃ ដូចជា រោគហឺត បញ្ហាមិនអាចយកចិត្តទុកដាក់បាន ជម្ងឺស្កន់ រោគបេះដូង រោគឈាមមិនកក ជម្ងឺមហារីកឈាម រោគរលាកតម្រងនោម រោគគ្រុនសន្លាក់ឆ្អឹង និង ជម្ងឺខ្វះឈាមក្រហម។/

**Other Health Impaired:** Term used to describe limited strength, vitality and alertness that results in decreased ability in the educational environment. Impairment could be a result of chronic health problems such as asthma, attention deficit disorder, epilepsy, heart condition, hemophilia, leukemia, nephritis, rheumatic fever and sickle cell anemia.

**ការយល់ព្រមរបស់មាតាបិតា៖** ពាក្យសម្រាប់ការអប់រំពិសេសប្រើដោយ**ច្បាប់អប់រំសិស្សពិការ (IDEA)** ដែលចែងថា គេបានផ្តល់ដំណឹងដល់លោកអ្នកជាភាសារបស់លោកអ្នកយ៉ាងក្បោះក្បាយ ឬការទាក់ទងតាមវិធីផ្សេងទៀត នៃព័ត៌មានទាំងអស់អំពី សកម្មភាពដែលលោកអ្នកនឹងផ្តល់ការយល់ព្រម ហើយលោកអ្នកយល់ និងយល់ព្រមតាមការសរសេរជាលាយល័ក្ខអក្សរ ទៅនឹងសកម្មភាពនោះ។/

**Parent Consent:** Special education term used by **Individuals with Disabilities Education Act (IDEA)** that states you have been fully informed in your native language or other mode of communication of all the information about the action for which you are giving consent and that you understand and agree in writing to that action.

**អ្នកព្យាបាលរាងកាយ៖** ផ្តល់ការពិគ្រោះ និងការគាំទ្រ ដល់បុគ្គលិក ដើម្បីបង្កើនការសិក្សារបស់សិស្ស ដែលទាក់ទងនឹងការប្រើសាច់ដុំធំដើម្បីធ្វើចលនា។/

**Physical Therapists:** Provide consultation and support to staff to improve a student's educational performance related to functional gross motor development.

**ឲ្យរៀននៅផ្ទះ ឬ នៅកន្លែងឯកជន៖** ផ្នែក B នៃ **ច្បាប់អប់រំសិស្សពិការ** មិនតម្រូវឲ្យក្រសួងអប់រំបង់ថ្លៃអប់រំសម្រាប់ក្មេងពិការរបស់លោកអ្នក នៅសាលា ឬកន្លែងឯកជនទេ បើសិនជាក្រសួងអប់រំផ្តល់ការអប់រំជាសាធារណៈដែលសមរម្យ ហើយដោយឥតគិតថ្លៃ ដល់កូនលោកអ្នក ហើយលោកអ្នកជ្រើសរើសឲ្យកូនទៅរៀន នៅសាលាឯកជនវិញ។/

**Residential and Private Placements:** Part B of **Individuals with Disabilities Education Act (IDEA)** does not require a school district to pay for the cost of education for your disabled child at a private school or facility if the school district made free appropriate public education available to your child and you chose to place your child in private placement.

**អ្នកចិត្តសាស្ត្រសម្រាប់សាលា៖** ជួយរកមើលសេចក្តីត្រូវការរបស់សិស្សានុសិស្សខាង បញ្ញាវាងវៃ ទំនាក់ទំនងក្នុងសង្គម និងអារម្មណ៍។ ពួកគេផ្តល់ការពិគ្រោះ និងការគាំទ្រ ដល់ក្រុមគ្រួសារ និងបុគ្គលិក ដែលទាក់ទងដល់ អាកប្បកិរិយា និងលក្ខណៈ ដែលទាក់ទងដល់ការសិក្សា។ ពួកគេគ្រោងកម្មវិធីដើម្បីឲ្យត្រូវតាមសេចក្តីត្រូវការរបស់ក្មេង ហើយតែងតែធ្វើជាអ្នកសម្រួលក្នុងពេលប្រជុំរៀបចំ**គម្រោងការអប់រំផ្ទាល់របស់ក្មេង**។/

**School Psychologist:** Assist in the identification of intellectual, social and emotional needs of students. They provide consultation and support to families and staff regarding behavior and conditions related to learning. They plan programs to meet the special needs of children and often serve as a facilitator during an **Individualized Education Plan (IEP)** meeting.

**មានបញ្ហាក្នុងការរៀនសូត្រអ្វីមួយ៖** ពាក្យសម្រាប់ការអប់រំពិសេស ប្រើដើម្បីឲ្យនិយមន័យនៃភាពខុសពីធម្មតា ក្នុងមូលដ្ឋានចិត្តសាស្ត្រមួយ ឬលើសពីមួយ ដែលទាក់ទងដល់ការយល់ដឹង ឬការប្រើភាសាក្នុងការនិយាយ ឬក្នុងការសរសេរ ដែលអាចបញ្ចេញឲ្យឃើញនូវការខ្វះសមត្ថភាពដើម្បី ស្តាប់ គិត និយាយ អាន សរសេរ ប្រកបអក្សរ ឬធ្វើគណិតវិទ្យា។/

**Specific Learning Disability:** Special education term used to define a disorder in one or more of the basic psychological processes involved in understanding or using language spoken or written that may manifest itself in an imperfect ability to listen, think, speak, read, write, spell or do mathematical computations.

**មានបញ្ហាក្នុងការនិយាយស្ដី និងបញ្ហាភាសា៖** បញ្ហាក្នុងការនិយាយស្ដី ដូចជា សំដីត្រដិត មិនអាចបញ្ចេញសម្លេងច្បាស់លាស់ មិនសូវចេះនិយាយ ឬខូចសម្លេង។/
**Speech and Language Impairments:** Communication disorders such as stuttering, impaired articulation, language impairment or voice impairment.

**អ្នកឯកទេសខាងបញ្ហាក្នុងការនិយាយស្ដី និងភាសា៖** វាយតម្លៃសិស្សានុសិស្សដើម្បីឲ្យដឹងពីការក្រចេះនិយាយ និងចំណេះដឹងខាងភាសា និងផ្តល់ការបង្រៀនផ្ទាល់ផ្នែក សទ្ទវិទ្យា រូបសព្ទវិទ្យា វាក្យសម្ព័ន្ធ និយណ្ឌសាស្ត្រ និងការសិក្សារបៀបប្រើភាសាក្នុងសង្គម។ ពួកគេក៏មានពេលសម្រាប់ការស្ដាប់មិនឮ និងការធ្វើឲ្យឮខ្លាំង ផងដែរ។/
**Speech and Language Specialists:** Assesses students for possible delayed speech and language skills and provides direct services in the area of phonology, morphology, syntax, semantics and pragmatics. They are also available regarding hearing impairments and amplification.

**Tourette's Syndrome:** អាការរោគដែលរួមមាន ចលនាច្រើនយ៉ាង និងសម្លេងញ័រ ដែលកើតមានឡើងច្រើនដងក្នុងមួយថ្ងៃ ស្ទើរតែរាល់ថ្ងៃ។ បើសិនជាក្មេងមាន Tourette's syndrome រោគសញ្ញាច្រើនកើតមានឡើងពេលក្មេងមាន អាយុ ៣-១០ ឆ្នាំ។/
Disorder that includes multiple motor and one or more vocal tics, which occur many times per day, nearly daily. If a child has Tourette's syndrome, symptoms tend to appear between the ages of 3-10 years old.

**របួសខួរក្បាលធ្ងន់ធ្ងរ៖** ជារបួសក្បាលដែលបណ្ដាលមកពីការប៉ះទង្គិចមកលើ រាងកាយ បណ្ដាលឲ្យពិការទាំងស្រុង ឬពិការមួយផ្នែក ឬខូចសតិ។ សម្រាប់របួសក្បាលដែល បែក ឬ មិនបែក។/
**Traumatic Brain Injury:** An acquired injury to the brain caused by an external physical force resulting in total or partial functional disability or psychosocial impairment. Applies to open or closed head injuries.

**មើលមិនសូវឃើញ៖** ការមើលមិនសូវឃើញ ទោះជាមានការកែតម្រូវ ក៏នៅតែមានឥទ្ធិពលអាក្រក់ដល់ការសិក្សារបស់ក្មេង។/
**Visual Impairment:** Impairment in vision that even with correction adversely affects a child's educational performance.

**អ្នកឯកទេសខាងភ្នែក៖** ផ្តល់ការពិភាក្សា និងការគាំទ្រ ដល់បុគ្គលិក និងការបង្រៀនផ្ទាល់ដល់សិស្សដែលមើលមិនឃើញ។ ពួកគេផ្តល់ការវាយតម្លៃភ្នែក និងកែសម្រួលកម្មវិធីសិក្សា រួមមាន ប្រព័ន្ធនៃការអាន និងសរសេរ (Braille) អក្សរពុម្ពធំៗ និងគ្រឿងស្ដាប់ (aural media)។/
**Vision Specialists:** Provide consultation and support to staff and direct instructional support to students with visual impairments. They provide functional vision assessments and curriculum modifications including Braille, large type and aural media.

**គម្រោងការ ៥០៤៖** សិស្សដែលគេបានកំណត់ថាមាន ភាពពិការ ប៉ុន្តែគ្មានការបង្ហាត់បង្រៀនដែលមានការរៀបចំពិសេស អាចមានការកែប្រែ និងការតម្រូវ ដែលពួកគេត្រូវការ ដើម្បីឲ្យពួកគេមានឱកាសរៀនសូត្រតាមកម្រិតដូចគ្នា នឹងសិស្សរួមថ្នាក់របស់ពួកគេ បានឲ្យនិយមន័យថា **គម្រោងការ ៥០៤**។ ឧទាហរណ៍ខ្លះៗនៃការបម្រើទាំងនេះអាចរួមមាន ច្រកជម្រាលសម្រាប់អ្នកពិការចេញចូល ការពិនិត្យឈាមផ្អែម សៀវភៅអានបន្ថែមមួយចំនួន អាហារពេលថ្ងៃដែលគ្មានសណ្ដែកដី ឬវិធីផ្សេងៗក្នុងការកត់ចំណាំនៅក្នុងថ្នាក់រៀន។/
**504 service plan:** A student who has a defined disability but does not require specially designed instruction, may have the modifications and accommodations they will need in order for them to have an opportunity perform at the same level as their peers, defined in a **504 service plan**. Some examples of services might include such things as wheelchair ramps, blood sugar monitoring, an extra set of textbooks, a peanut-free lunch environment, or alternate ways of taking notes in class.